# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.០៣០.......សហវ. ១១៣៨

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារពេលលើកទី២ សម្រាប់ការបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១១

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនលោក លោកស្រីដែលជាម្ចាស់អចលនទ្រព្យស្ថិតនៅក្នុងរដ្ឋបាលដែនដីខណ្ឌនៃរាជធានី និងស្ថិតនៅក្នុងរដ្ឋបាលដែនដីក្រុងនៃខេត្តនានា មេត្តាជ្រាបថា ក្រោយការរំលឹកការបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១ កន្លងមកនេះ ឃើញថា លោក លោកស្រីដែលជាម្ចាស់អចលនទ្រព្យជាច្រើន បានរួសរាន់មកប្រកាសបង់ពន្ធយ៉ាងសសាក់សស្រាំ ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមសំដែងមូលវិចារណ៍ថ្លៃថ្លាចំពោះស្មារតីទទួលខុសត្រូវខ្ពស់របស់លោក លោកស្រីដែលជាម្ចាស់អចលនទ្រព្យ ក្នុងការបំពេញកាតព្វកិច្ចពន្ធដារនេះ ។

ដោយសារចំនួនមន្ត្រីពន្ធដារនៅមានកម្រិត សាខាពន្ធដារខេត្ត-ខណ្ឌមួយចំនួនមិនអាចផ្តល់សេវាបានទាន់ពេលវេលា ដល់លោក លោកស្រីដែលជាម្ចាស់អចលនទ្រព្យដែលមកប្រកាសបង់ពន្ធ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមពន្យារពេលការប្រមូលពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១១នេះ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង ១៧ : ៣០ នាទីរសៀល ហើយសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ នឹងទទួលការចុះបញ្ជី ការដាក់លិខិតប្រកាសពន្ធ និងការបង់ពន្ធលើអចលនទ្រព្យ នៅរៀងរាល់ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ បន្ថែមទៀត តាមម៉ោងការងាររដ្ឋបាលនៃថ្ងៃធ្វើការធម្មតា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមរំលឹកជាថ្មីម្តងទៀតដល់លោក លោកស្រីដែលជាម្ចាស់អចលនទ្រព្យដែលពុំទាន់បានបំពេញកាតព្វកិច្ចបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១១នេះ មេត្តារួសរាន់មកប្រកាសបង់ពន្ធឱ្យទាន់ពេលវេលា មុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង ១៧:៣០ នាទីរសៀល ជៀសវាងនូវការប្រជ្រៀតគ្នានៅថ្ងៃជិតផុតកំណត់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រីដែលជាម្ចាស់អចលនទ្រព្យ មានស្មារតីគោរពច្បាប់ និងអញ្ជើញមកប្រកាសបង់ពន្ធតាមកាលកំណត់ជាពុំខាន ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com